**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ សូមគាំទ្រទាំងស្រុង និងយ៉ាងពេញទំហឹង ចំពោះសាលដីកាស្ថាពរ របស់តុលាការកំពូលនាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការកាត់ទោស «រំលាយគណបក្សសង្គ្រោះជាតិ» និងផ្អាកសកម្មភាពនយោបាយរយៈពេល៥ឆ្នាំចំពោះថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិចំនួន ១១៨ រូប គឺពិតជាស័ក្តិសមទៅនឹងទោសកំហុស នៃទង្វើក្បត់ជាតិរបស់គណបក្សមួយនេះ ដែលមិនអាចអត់ឱនឲ្យបាននោះឡើយ។

យើងខ្ញុំទាំងអស់គ្នា សូមគាំទ្រចំពោះវិធានការបន្តដែលបានដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការបន្តទប់ស្កាត់ឧបាយកលបដិវត្តន៍ពណ៌នៅកម្ពុជា។ ប្តេជ្ញាថែរក្សាការពារសន្តិសុខ សន្តិភាពនិងការអភិវឌ្ឍនៅកម្ពុជា ប្រឆាំងទប់ស្កាត់បក្សនយោបាយ និងក្រុមអ្នកនយោបាយដែលឃុបឃិតនិងបម្រើផលប្រយោជន៍បរទេស។ ប្តេជ្ញាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃកម្ពុជា ប្រឆាំងនិងការជ្រៀតជ្រែកទាំងឡាយរបស់បរទេស។ ប្តេជ្ញាគាំទ្រការអនុវត្តវិធានការច្បាប់ និងការគោរពច្បាប់ក្នុងសង្គមដើម្បីពង្រឹងនីតិរដ្ឋនៅកម្ពុជា។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ សូមប្រកាសគាំទ្រយ៉ាងឧឡារិក ចំពោះសាលដីការបស់តុលាការកំពូលដែលបានកាត់ទោស «រំលាយគណបក្សសង្គ្រោះជាតិ» សូមគាំទ្រនិងសម្តែងនូវភក្តីភាពយ៉ាងស្មោះស្ម័គ្រចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយគតិបណ្ឌិត របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែបានបូជា កម្លាំងកាយ កម្លាំងចិត្ត និងប្រកាន់ភ្ជាប់នូវឧត្តមគតិស្នេហាជាតិដ៏ឧត្តុង្គឧត្តម ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា និងជោគវាសនាប្រទេសជាតិនិងមាតុភូមិទាំងមូល។

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការ ចំពោះទង្វើក្បត់ជាតិរបស់គណបក្សសង្គ្រោះជាតិ និងថ្នាក់ដឹកនាំក៏ដូចជាជនអគតិមួយចំនួនដែលបានឃុបឃិតជាមួយបរទេស ព្រមទាំងប្រឆាំងដាច់ខាត រាល់ឧបាយកលបដិវត្តន៍ពណ៌មិនឱ្យនាំមកនូវសង្គ្រាមវិនាសសកម្មនិងគ្រោះមហន្តរាយជាថ្មីម្តងទៀតនៅកម្ពុជានោះឡើយ។

សូមអំពាវនាវឲ្យមានការចាត់វិធានការផ្លូវច្បាប់ជាបន្តបន្ទាប់ឱ្យបានម៉ឺងម៉ាត់បំផុត ដើម្បីពង្រឹងនីតិរដ្ឋ ក្នុងគោលបំណងថែរក្សា សន្តិភាព ស្ថិរភាពសង្គម សណ្តាប់ធ្នាប់សាធារណៈ និងដើម្បីភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**រដ្ឋមន្ត្រីស្តីទី**

**នាយឧត្តមសេនីយ៍ ទា បាញ់ សាំងយុន**